លេខ: GTPR-២៣១១-០០២

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការរឹបអូសបណ្តោះអាសន្នលើអគារស្នាក់នៅរបស់ ក្រុមហ៊ុន ហ្គោលដេន ទ្រី

ក្រុមហ៊ុន **ហ្គោលដេន ទ្រី** ("**ក្រុមហ៊ុន**") ដែលជាក្រុមហ៊ុនបោះផ្សាយមូលបត្របំណុលបៃតងដំបូងគេនៅកម្ពុជា និង បានចុះបញ្ជីលើទីផ្សារ មូលបត្រកម្ពុជា (**ផមក**) កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ មានកិត្តិយសសូមជម្រាបជូនវិនិយោគិន និងសាធារណជនមេត្តាជ្រាបថា៖

ក្រុមហ៊ុនបានទិញ អគារស្នាក់នៅមួយកន្លែង (ឈ្មោះថា **អគារអមម៉ា រេស៊ីដេន**) ដែលមានអាសយដ្ឋាននៅផ្លូវលេខ ៤១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០២២ ដែលមានឈ្មោះ **គុយ វ៉ាត** ជាសហកម្មសិទ្ធករ ដោយប្រើប្រាស់ប្រាក់កម្ចីពីធនាគារ និងសាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយសញ្ញាបណ្ណបៃតង អនុលោមតាមគោលការណ៍ និងលក្ខខណ្ឌតម្រូវដើម្បី ប្រែក្លាយអគារនេះ ទៅជាអគារស្នាក់នៅបៃតង ដូចដែលក្រុមហ៊ុនបានផ្សព្វផ្សាយជាសារធារណៈ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ២០២២ របស់ក្រុមហ៊ុន និងរបាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មឆ្នាំ២០២២ ពីសវនកររឯករាជ្យផងដែរ។ សូមបញ្ជាក់ផងដែរថាចាប់តាំងថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣ ឈ្មោះ **គុយ វ៉ាត** លែងជាភាគហ៊ុនិករបស់ក្រុមហ៊ុន ហើយក៏ពុំមានតួនាទីអ្វីនៅក្នុងក្រុមហ៊ុនទៀតឡើយ។

ក្នុងកំឡុងពេលដំណើរការផ្ទេរ កម្មសិទ្ធិលើអាគារខាងលើ ក្រុមហ៊ុនបានទទួលដំណឹងពីការរឹបអូសបណ្តោះអាសន្នដោយដីកាសម្រេចលេខ២៧៥"ង១"ដ.រ ចុះថ្ងៃទី២៩-០៦-២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ លើទ្រព្យសម្បត្តិរបស់កូនបំណុលឈ្មោះ **គុយ វ៉ាត** ក្នុងនោះមានដី និងអគារដែលត្រូវទិញដោយក្រុមហ៊ុន។ ដីកាសម្រេចនេះបានធ្វើឲ្យរាំងស្ទះដល់ការចុះបញ្ជីផ្ទេរកម្មសិទ្ធិពីឈ្មោះ **គុយ វ៉ាត** មកក្រោមឈ្មោះក្រុមហ៊ុន តាមច្បាប់ជាធរមាន។

ចំពោះបញ្ហាខាងលើនេះ ក្រុមហ៊ុនកំពុងចាត់វិធានការតាមផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងប្រុងប្រយ័ត្ន តវ៉ានឹងដីកាសម្រេចខាងលើ ក្នុងគោលបំណង រក្សាការពារផលប្រយោជន៍និងកេរ្តិ៍ឈ្មោះរបស់ខ្លួន ព្រមទាំងធានានូវតម្លាភាព និងគណនេយ្យភាព ចំពោះវិនិយោគិន និងភាគីពាក់ពន្ធ័ផ្សេងទៀតទាំងអស់។

ក្រុមហ៊ុនសូមបញ្ជាក់ថាព្រឹត្តិការណ៍នេះមិនមានផលប៉ះពាល់ទៅលើការបំពេញកាតព្វកិច្ចរបស់ក្រុមហ៊ុន ចំពោះម្ចាស់មូលបត្របំណុលដែលមានដូចជា ការបង់ការប្រាក់ និងការសងប្រាក់ដើមនោះឡើយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនមេត្តាទទួលជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃ ច័ន្ទ ០៨ កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ត្រូវនឹង ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ក្រុមហ៊ុន ហ្គោលដេន ទ្រី**